# 소망의 여인들

**Prayer Calander**

**2025년 1월**

**ប្រតិទិនអធិស្ឋានចេញផ្សាយជារៀងរាល់ខែ ដែលមានជាង 100ភាសា និងមានអ្នកចូលរួមអធិស្ឋានជាង 110,000នាក់**



## កា ការអធិស្ឋានសម្រាប់ស្ត្រីអឺរ៉ុប

ឆ្នាំថ្មីឆ្នាំ 2025 បានមកដល់ហើយ។ តើកម្លាំងរបស់អ្នកក្នុងការដែលរស់នៅដូចព្រះយេស៊ូបានមកពីណា? ការមានទំនាក់ទំនងជាមួយព្រះ ហើយការដាក់ខ្លួនយើងដោយក្តីស្រឡាញ់ និងការគោរពប្រតិបត្តិព្រះដោយបន្ទាបខ្លួន។ ពេលនោះ ព្រះវិញ្ញាណបរិសុទ្ធដែលគង់នៅក្នុងយើងនឹងប្រទានកម្លាំងដល់យើង។ តែឯអ្នក ចូរឲ្យអ្នកនៅជាប់ក្នុងសេចក្តីដែលអ្នកបានរៀន ហើយជឿប្រាកដវិញ ដោយដឹងថា អ្នកបានរៀនសេចក្តីនោះពីអ្នកណា ហើយថា តាំងពីក្មេងតូចមក អ្នកបានស្គាល់បទគម្ពីរទាំងប៉ុន្មាន ដែលអាចនឹងនាំឲ្យអ្នកមានប្រាជ្ញាដល់ទីសង្គ្រោះ ដែលបានដោយសារសេចក្តីជំនឿជឿដល់ព្រះគ្រីស្ទយេស៊ូវផង ។២ ធីម៉ូថេ ៣:១៥-១៥ ក្នុងខែឧសភា ឆ្នាំ២០២៥ គឺជាឆ្នាំដែលយើងគួមើលតែព្រះអម្ចាស់ដែលល្អ និងស្រស់ស្អាត ហើយដើរជាមួយនឹងទ្រង់។

카카오톡 채널에서 '소망의 여인들' 채널을 추가하시면 매주 월요일에 한국어 기도카드를 받으실 수 있습니다.

1. ព្រះអម្ចាស់អើយ សូមប្រទានប្រាជ្ញា និងគំនិតច្នៃប្រឌិតដល់ក្រុមការងារដែលផលិតរឿង ក៏ដូចជាកម្មវិធី កំណប់មរតក ភាគ២។ សូមឱ្យកម្មវិធីនេះបានជាព្រះពរដល់អ្នកដែលបានចាកចេញពីអំពើរពេស្យាចារ ហើយកំពុងដើរតាមទ្រង់ក្នុងជីវិតថ្មីរបស់ពួកគេ។ (២កូរិនថូស ៥:១៧)

2. ព្រះអម្ចាស់អើយ ក្នុងការដែលក្រុមរបស់យើងនៅក្នុងប្រទេសអាល់បានីបម្រើស្ត្រីដែលចាកចេញពីស្ថានភាពដែលពាក់ព័ន្ធនឹងអំពើហិង្សាក្នុងគ្រួសារ សូមអនុញ្ញាតឱ្យពួកគេនាំស្ត្រីទាំងនេះទៅកាន់ព្រះយេស៊ូវ ហើយជួយពួកគេមានទំនាក់ទំនងជាមួយព្រះវិហារ និងអង្គការក្នុងស្រុកដែលអាចជួយគេបាន។ (ហេព្រើរ ១៣:១៦)

3. ព្រះវរបិតាអើយ សូមជួយស្ត្រីគ្រីស្ទាននៅប្រទេសក្រូអាត អោយមានទំនាក់ទំនងល្អជាមួយគ្នា ដើម្បីគាំទ្រ ប្រកប និងពង្រឹងជំនឿរបស់ពួកគេ ក្នុងការប្រឈមមុខនឹងបញ្ហាប្រចាំថ្ងៃរបស់ពួកគេ។ ( ថែស្សាទី១ ៥:១១ )

4. ព្រះអម្ចាស់អើយ សូមទ្រង់ជួយសម្រាលទុក្ខក្មេងស្រីនៅប្រទេសដាណឺម៉ាក ដែលយល់ច្រលំអំពីភេទរបស់ពួកគេ។ ណែនាំពួកគេឱ្យទទួលយកអត្តសញ្ញាណពិតដែលទ្រង់បានផ្តល់ឱ្យពួកគេ។ (លោកុប្បត្តិ ១:២៧)

5. ព្រះអម្ចាស់អើយ យើងលើកសរសើរចំពោះភាពស្មោះត្រង់របស់ទ្រង់ នៅពេលដែលក្រុមការងារស្ត្រីក្នុងក្តីសង្ឃឹមនៅប្រទេសហូឡង់ប្រារព្ធខួបលើកទី25 របស់ពួកគេ។ យើងសូមអរព្រះគុណទ្រង់ចំពោះក្រុមអធិស្ឋានជាង 90 នៅទូទាំងប្រទេសនេះផងដែរ។ (បរិទេវ ៣:២២-២៣)

6. ឱព្រះវរបិតាអើយ សូមទ្រង់ការពារពួកគ្រិស្តបរិស័ទ និងសាសន៍យូដានៅប្រទេសបារាំង ដែលត្រូវបានវាយប្រហារ ឬសម្លាប់ដោយសារជំនឿរបស់ពួកគេ។ សូមឱ្យអ្នកដែលមានបេះដូងពោរពេញដោយសេចក្តីស្អប់ត្រូវបានផ្លាស់ប្តូរដោយព្រះនាមរបស់ទ្រង់។ (ទំនុកតម្កើង ១៤០:១)

7. ព្រះជាអម្ចាស់ យើងខ្ញុំអធិស្ឋានសូមឱ្យជនរងគ្រោះនៃការជួញដូរមនុស្សដែលធ្វើការនៅតំបន់ភ្លើងក្រហមរបស់ប្រទេសអាល្លឺម៉ង់ ទទួលបានជំនួយ ដើម្បីចាប់ផ្តើមជីវិតថ្មីរស់ក្នុងសេរីភាព។ (ទំនុកតម្កើង ១១៩:១៣៤)

8.សូមអោយប្រជាជននៅហ្វាំងឡង់បានរួចផុតពីគ្រឿងស្រវឹង និងគ្រឿងញៀនដែលបំផ្លាញគ្រួសារ និងនាំពួកគេទៅរកការរំលោភបំពាន និងការធ្វើអត្តឃាត។ ព្រះយេស៊ូវ អើយ សូមជះពន្លឺរបស់ទ្រង់ទៅក្នុងភាពងងឹតរបស់ពួកគេ។ (យ៉ូហាន ៨:១២)

9.ក្មេងស្រីជំទង់ជាច្រើននៅប្រទេសហូឡង់កំពុងតយុទ្ធជាមួយនឹងជំងឺធ្លាក់ទឹកចិត្ត។ សូមឲ្យពួកគេទទួលបានជំនួយដែលពួកគេត្រូវការ ហើយរកឃើញការកំសាន្តចិត្តដ៏ពិតប្រាកដ និងបានសម្រាកនៅក្នុងទ្រង់។ (ម៉ាថាយ ១១:២៨)

10. ឱព្រះវរបិតាអើយ សូមប្រោសស្ត្រីមកពីភាគខាងជើង Caucasus ឱ្យរួចផុតពីការវិនិច្ឆ័យក្នុងសង្គម និងគ្រួសារ ដោយផ្តល់ឱ្យពួកគេនូវភាពក្លាហានក្នុងការដើរតាមព្រះគ្រីស្ទ ដោយបើកចំហ ហើយថ្លែងពីទីបន្ទាល់ចំពោះសេចក្តីជំនឿរបស់ពួកគេផងដែរ។ (អេសាយ ៤១:១៣)

11. បិតាអើយ សូមឲ្យកម្មវិធី តម្លៃ និងជាទីស្រឡាញ់ បានលឺហើយមានការប៉ះពាល់ចិត្តដល់ស្ត្រីនៅម៉ាសេដូនខាងជើង ដើម្បីនាំមកនូវក្តីសង្ឃឹម ការព្យាបាល និងសេរីភាព ជាពិសេសស្ត្រីដែលនៅក្នុងចំណោមសាសនាដែលមានឥទ្ធិពលដែលនៅទីនោះ។ (ទំនុកតម្កើង ៣៤:១៨)

**TWR Korea 북방선교방송**

서울특별시 관악구 양녕로 15, 월드빌딩 6층

전화 (02)886-5671 / 이메일 hskim@twrk.or.kr

12.សូមអោយគ្រិស្តបរិស័ទនៅន័រវេសបានស្វាគមន៍យ៉ាងកក់ក្តៅចំពោះស្រ្តីអន្តោប្រវេសន៍ដែលប្រឈមមុខនឹងឧបសគ្គខាងភាសា វប្បធម៌ ភាពឯកោ និងការរើសអើង។ (លេវីវិន័យ ១៩:៣៤)

13. ព្រះអម្ចាស់អើយ សូមប្រោសប្រទាននូវប្រាជ្ញា និងការយល់ដឹងដល់អ្នកគ្រប់គ្រង និងក្រុមប្រឆាំងនយោបាយនៅក្នុងប្រទេសប៉ូឡូញ ដើម្បីឱ្យពួកគេអាចសហការ និងដឹកនាំប្រទេសនេះ។ (យេរេមា ២៩:៧)

14. យើងអធិស្ឋាន ព្រះអម្ចាស់អើយ សម្រាប់សំណងសមរម្យក្នុងការងារ និងបង្កើនឱកាសក្នុងសង្គមសម្រាប់ស្ត្រីនៅក្នុងប្រទេសព័រទុយហ្គាល់។ (ទំនុកតម្កើង ៣៤:១៥)

15. នៅពេលដែលការលែងលះកើនឡើងនៅក្នុងប្រទេសរ៉ូម៉ានី បិតាអើយ សូមជួយគូស្វាមីភរិយាដែលកំពុងតែមានការមិនចុះសម្រុងគ្នា បានតស៊ូដើម្បីជួយគ្រួសាររបស់ពួកគេដោយជោគជ័យ។ (ម៉ាកុស ១០:៩)

16. ព្រះអង្គអើយ សូមអោយស្ត្រីនៅក្នុងប្រទេសរុស្ស៊ីស្វែងរកទំនាក់ទំនងផ្ទាល់ខ្លួនជាមួយទ្រង់ មានការរីកចម្រើនក្នុងជំនឿរបស់ពួកគេ ហើយស្វែងរកការលួងលោម និងកម្លាំងនៅក្នុងទ្រង់សម្រាប់ជីវិតរបស់ពួកគេផងដែរ។ (អេភេសូរ ៣:១៦)

17. ព្រះអម្ចាស់អើយ សូមនាំមកនូវសន្តិភាព និងសុភមង្គលដល់គ្រួសារនៅក្នុងប្រទេសស៊ែប៊ី។ សូមឲ្យស្ត្រីទទួលស្គាល់នូវតម្លៃ និងសក្តានុពលរបស់ខ្លួនគេក្នុងទ្រង់ ហើយធ្វើកាន់ភ្ជាប់នូវសេចក្តីស្រឡាញ់ ការយោគយល់ និងសេចក្តីជំនឿរបស់ពួកគេ។ (១ពេត្រុស ៣:៩)

18.នៅពេលដែលអត្រានៃការធ្វើអត្តឃាតកើនឡើងនៅក្នុងប្រទេសអេស្ប៉ាញ កូនអធិស្ឋាន សូមអោយស្ត្រីវ័យក្មេងរៀនទប់ចិត្តរបស់ពួកគេពីការមិនពិតប្រាកដនៃប្រព័ន្ធផ្សព្វផ្សាយសង្គមនេះ។ (ទំនុកតម្កើង ១៤៧:៣)

19. ព្រះអម្ចាស់អើយ យើងអធិស្ឋានសម្រាប់ក្មេងកំព្រានៅប្រទេសអាល់បានី និងកុមារដែលឪពុកម្តាយរបស់ពួកគេបោះបង់ចោល។ សូមឲ្យក្រុមជំនុំផ្តល់សេចក្តីស្រឡាញ់ដល់ពួកគេ ហើយនាំពួកគេទៅរកព្រះយេស៊ូវផងដែរ ។ (ចោទិយកថា ១០:១៨)

20. ព្រះវរបិតាអើយ សូមប្រើកម្មវិធី Arise and Shine ដើម្បីប៉ះពាល់ លើកទឹកចិត្ត និងពង្រឹងដួងចិត្តរបស់ស្ត្រីនៅបែលហ្ស៊ិក និងហូឡង់ ដើម្បីរស់នៅដោយបើកចំហនូវសេចក្តីជំនឿរបស់ពួកគេ។ (អេសាយ ៦០:១)

21.សូមឱ្យស្ត្រីនៅប្រទេសក្រូអាស៊ីទទួលស្គាល់តម្លៃរបស់ពួកគេនៅក្នុងព្រះគ្រីស្ទ សូមជួយគេអោយរួចផុតពីការភ័យខ្លាច និងភាពអសន្តិសុខ ហើយឈានជើងចូលទៅក្នុងសេរីភាព និងទំនុកចិត្តដែលមាននៅក្នុងទ្រង់ផងដែរ។ (ម៉ាថាយ ១០:៣១)

22.សូមអោយស្ត្រីនៅប្រទេសដាណឺម៉ាកដែលរស់នៅជាមួយភាពភ័យខ្លាចនៃការបដិសេធ ការរំលោភបំពាន ភាពឯកកោ ភាពស្រេកឃ្លាន ឬការគ្មានផ្ទះសម្បែង សូមអោយពួកគេបានទុកចិត្តលើទ្រង់ បិតាអើយ សូមទ្រង់ធ្វើជាអ្នកការពារ ប្រទាន និងធ្វើជាក្តីសង្ឃឹមរបស់ពួកគេផងដែរ។ (ទំនុកដំកើង ១៨:២)

23. បិតាអើយ សូមបញ្ឈប់ការប្រើប្រាស់គ្រឿងញៀន និងគ្រឿងស្រវឹងនៅកោះហ្វារ៉ូ ហើយផ្សះផ្សារឡើងវិញគ្រួសារដែលត្រូវបាក់បែកដោយសារធាតុទាំងនេះ។ ជួយពួកគេឱ្យស្វែងរកសេចក្តីស្រឡាញ់ និងការព្យាបាលនៅក្នុងទ្រង់។ (យ៉ូហាន ៣:១៦)

24. ការស្ទង់មតិឆ្នាំ 2021 បានបង្ហាញថា ពលរដ្ឋជាងពាក់កណ្តាលនៃប្រទេសបារាំបានឈប់ជឿលើព្រះ ហើយចាត់ទុកសាសនាគ្រីស្តថាមិនពាក់ព័ន្ធ។ សូមពង្រឹងសេចក្តីជំនឿអ្នកជឿពិតដើម្បីចូលទៅរកមនុស្សដែលមិនប្រកាន់សាសនាដោយសេចក្តីស្រឡាញ់ និងសេចក្តីពិតរបស់ទ្រង់។ (លូកា ១៨:៨)

25. យើងសូមសរសើរព្រះនាមទ្រង់ ចំពោះក្រុមអធិស្ឋានជនជាតិអាឡឺម៉ង់ ដែលអធិស្ឋានដោយចិត្តស្មោះសរជាមួយប្រតិទិនអធិស្ឋាន និងសម្រាប់ម្ចាស់ជំនួយដែលអាចឱ្យយើងគាំទ្រកម្មវិធីស្ត្រីក្នុងក្តីស្នឹមជាភាសាផ្សេងៗគ្នាផងដែរ។ (ភីលីព ១:៣-៥)

26.សូមឲ្យស្ត្រីជនជាតិន័រវេសមើលឃើញពីតម្លៃនៃការជួបជុំគ្នាក្នុងក្រុមអធិស្ឋាន ការចែករំលែកសេចក្តីអំណរ និងទុក្ខព្រួយ ការអធិស្ឋានសម្រាប់គ្នាទៅវិញទៅមក និងការអធិស្ឋានសម្រាប់ស្ត្រីនៅជុំវិញពិភពលោកផងដែរ។ (ម៉ាថាយ ១៨:២០)

27. ព្រះវរបិតាអើយ យើងអធិស្ឋានសូមអោយកម្មវិធីសិក្សារបស់សាលាប៉ូឡូញនឹងលើកកម្ពស់គំរូគ្រួសារ ដែលស្របតាមឆន្ទះរបស់ទ្រង់។ (ម៉ាថាយ ១៩:៤-៥)

28. ព្រះអម្ចាស់អើយ សូមអោយស្ត្រីជនជាតិព័រទុយហ្គាល់ដែលមានអារម្មណ៍ធុញថប់ ខណៈពេលដែលកំពុងព្យាយាមផ្សះផ្សាគ្រួសារ ជីវិត និងអាជីពរបស់ពួកគេបានស្វែងរកការសម្រាករបស់ពួកគេនៅក្នុងទ្រង់ និងនៅពេលពួកគេរកមើលព្រះបន្ទូលរបស់ទ្រង់សម្រាប់ការដឹកនាំជីវិត។ (ម៉ាថាយ ១១:២៩)

29. នៅក្នុងសេដ្ឋកិច្ចដ៏លំបាកនេះ ព្រះអម្ចាស់អើយ សូមប្រទានប្រាជ្ញាដល់ស្ត្រីជនជាតិរ៉ូម៉ានី ដើម្បីគ្រប់គ្រងធនធានរបស់ពួកគេឱ្យបានល្អ និងយល់ថាទ្រង់គឺជាប្រភពនៃពរជ័យទាំងអស់។ (យ៉ាកុប ១:១៧)

30. ព្រះបិតាអើយ សូមផ្តល់ប្រាជ្ញាដល់ក្រុមការងាររបស់យើងនៅប្រទេសស៊ែប៊ី នៅពេលពួកគេសរសេរ និងផលិតកម្មវិធី។ សូមឲ្យពួកគេជ្រើសរើសប្រធានបទដែលនឹងផ្លាស់ប្តូរជីវិតស្ត្រីដែលស្តាប់ជាវិជ្ជមាន។ (យ៉ាកុប ១:៥)

31. ព្រះអម្ចាស់អើយ សូមអោយស្ត្រីនៅប្រទេសអេស្ប៉ាញដែលនៅម្នាក់ឯងដោយគ្មានធនធាន ហើយមានបំណងចង់បន្តការមានគភ៌របស់ពួកគេ ស្វែងរកការគាំទ្រដែលពួកគេត្រូវការ។ (ទំនុកតម្កើង ៣២:៨)

**후원안내**
**국민은행 851-01-0003-724 북방선교방송**
**최초 입금 후 사무실로 연락주시기 바랍니다.**